មើលវីដេអូ ភាគទី ៣៥

## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Moral Consciousness, unprompted, accompanied by indifference, associated with knowledge (wisdom).

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៧ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណចេតសិក ២៥



## ៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញាមានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។ Moral Consciousness, prompted, accompanied by indifference, associated with knowledge (wisdom).

** មានចេតសិកកើតរួមជាមួយ ៣៧ ដូចដួងទី ៥។*

## ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Moral Consciousness, unprompted, accompanied by indifference, dissociated with knowledge (wisdom).

# ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មានចេតសិកកើតរួម
ជាមួយ ៣៦ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណចេតសិក ២៤ (វៀរបញ្ញា)



## ៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាក បញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

Moral Consciousness, prompted, accompanied by indifference, dissociated with knowledge (wisdom).

* *មានចេតសិកកើតរួមជាមួយ ៣៦ ដូចដួងទី ៧។*

# អត្ថរបស់កុសល ៥ យ៉ាង

១. អរោគ្យត្ថ ដោយអត្ថថាមិនមានរោគ
(រាគៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ឥស្សា មច្ឆរិយៈ ជាដើម ឈ្មោះថា រោគ ព្រោះជាគ្រឿងចាក់ដោតញាំញីនូវសន្តានចិត្តឱ្យញាប់ញ័រក្តៅក្រហាយ)។

២. សុន្ទរត្ថ ដោយអត្ថថា ស្អាតបរិសុទ្ធល្អ។

៣. ឆេកត្ថ ដោយអត្ថថា ឆ្លាតវៃ ឬ មុតស្រួច
ក្នុងការកំចាត់បង់នូវភាពសៅហ្មងរបស់ចិត្ត។

៤. អនវជ្ជត្ថ ដោយអត្ថថា មិនមានទោស។

៥. សុខវិបាកត្ថ ដោយអត្ថថា មានវិបាកជាសុខ។